# ករណីសង្ខេបរបស់លោក កើត សារ៉ាយ



លោក **កើត សារ៉ាយ** គឺជាអ្នកការពារសិទ្ធិមនុស្សវ័យ ៣៤ ឆ្នាំ មានស្រុកកំណើតនៅខេត្តសៀមរាប។ លោកបានបួសជាព្រះសង្ឃនៅឆ្នាំ២០០២ ។ ក្នុងអំឡុងពេលសិក្សាច្បាប់នៅសាកលវិទ្យាល័យព្រះសីហនុរាជ លោកបានចាប់អារម្មណ៍កាន់តែខ្លាំងលើសកម្មភាពពាក់ព័ន្ធនឹងការការពារធនធានធម្មជាតិ និងការតស៊ូមតិដើម្បីសិទ្ធិមនុស្ស។ លោកបានចូលរួមជាមួយចលនាមាតាធម្មជាតិក្នុងនៅឆ្នាំ២០១៨ ។ នៅដើមឆ្នាំ២០២០ លោក កើត សារ៉ាយ រួមជាមួយសកម្មជនមួយចំនួនទៀតបានបង្កើតក្រុមយុវជនខ្មែរថេរវៈ ក្នុងគោលបំណងតស៊ូមតិដើម្បីសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម។ ក្រោយមក លោកបានក្លាយជាប្រធានសមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ ដែលលើកទឹកចិត្តដល់ការចូលរួមរបស់យុវជនក្នុងដើម្បីយុត្តិធម៌សង្គម ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ។

## កាលប្បវត្តិសង្ខេបករណី

**៦ កញ្ញា ២០២០៖**

លោក កើត សារ៉ាយ ត្រូវបាននគរបាលចាប់ខ្លួនជាលើកដំបូងនៅការិយាល័យសមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ ដោយសារតែផែនការរបស់លោកក្នុងការចូលរួមក្នុងការជួបជុំដោយសន្តិវិធីមួយដែលគ្រោងធ្វើឡើងនៅថ្ងៃបន្ទាប់ នៅក្នុងរាជធានីភ្នំពេញ ដើម្បីតវ៉ានឹងការចាប់ខ្លួនលោក រ៉ុង ឈុន ដែលជាសកម្មជននយោបាយនិងមេសហជីព ព្រមទាំងអ្នកការពារសិទ្ធិមនុស្ស លោក ហ៊ិន វណ្ណៈ និងកញ្ញា ឈឿន ដារ៉ាវី។ លោកបានផ្សព្វផ្សាយអំពីការធ្វើបាតុកម្មនេះនៅលើទំព័រហ្វេសប៊ុកផ្ទាល់ខ្លួនរបស់លោកនៅចុងខែសីហា។ រដ្ឋបាលរាជធានីភ្នំពេញបានឆ្លើយតបទៅនឹងលិខិតជូនដំណឹងពីអ្នករៀបចំថា ខ្លួនមិនអនុញ្ញាតចំពោះការរៀបចំនេះទេ ដោយលើកឡើងថា អ្នករៀបចំមិនអាចផ្តល់ការធានាចំពោះចំនួនអ្នកចូលរួមបាន។

នៅថ្ងៃដដែលនោះ លោក កើត សារ៉ាយ ត្រូវបានផ្ញើកមុនពេលបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ។ លោកត្រូវបានចោទប្រកាន់ពីបទ «ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម» (តាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ)។

**៧ កញ្ញា ២០២០៖**

លោក កើត សារ៉ាយ ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលអប់រំកែប្រែទី១ (ម១) ក្នុងរាជធានីភ្នំពេញ។

**៣០ ធ្នូ ២០២០៖**

សាលាដំបូងរាជធានីភ្នំពេញបានចាប់ផ្តើមបើកសវនាការករណីលោក កើត សារ៉ាយ។ លោកត្រូវបានជំនុំជម្រះទោសជាមួយអ្នកការពារសិទ្ធិមនុស្សមួយចំនួនទៀត ដែលត្រូវបានចាប់ខ្លួនក្នុងអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០២០ ដោយសារការចូលរួម ឬមានបំណងចូលរួមក្នុងបាតុកម្មតវ៉ាចំពោះការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស និងសកម្មជននយោបាយ។

**១៦ កុម្ភៈ ២០២១៖**

សាលាដំបូងរាជធានីភ្នំពេញបានបានបន្តសវនាការ។ សវនាការបន្ទាប់ដែលកំណត់សម្រាប់ថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ ត្រូវបានលើកពេលរហូតដល់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ និងលើកពេលបន្ថែមទៀតដោយគ្មានកាលកំណត់ ដោយសារជំងឺកូវីដ-១៩ ។

**១៨ ឧសភា ២០២១៖**

សាលាដំបូងរាជធានីភ្នំពេញបដិសេធសំណើសុំនៅក្រៅឃុំរបស់លោក កើត សារ៉ាយ។

**២៦ តុលា ២០២១៖**

លោក កើត សារ៉ាយ ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ២០ ខែ ប៉ុន្តែត្រូវព្យួរទោសពន្ធនាគាររយៈពេល ៦ ខែ។

**៥ វិច្ឆកា ២០២១៖**

លោក កើត សារ៉ាយ ត្រូវបានដោះលែងចេញពីពន្ធនាគារបន្ទាប់ពីជាប់ឃុំអស់រយៈពេល ១៤ ខែ។ សាលាដំបូងរាជធានីភ្នំពេញ បានបង្គាប់ស្ថិតក្រោមការសាកល្បងក្នុងលក្ខខណ្ឌតឹងរឹងរយៈពេលពីរឆ្នាំសម្រាប់លោក ហូតដល់ខែវិច្ឆិកា ឆ្នាំ ២០២៣ ។

**២២ សីហា ២០២២៖**

សាលាឧទ្ធរណ៍ភ្នំពេញតម្កល់សាលក្រមផ្តន្ទាទោសលោក កើត សារ៉ាយ។

**១៩ ឧសភា ២០២៣៖**

តុលាការកំពូលតម្កល់សាលដីការបស់សាលាឧទ្ធរណ៍។

**មីនា ២០២៤៖**

លោក កើត សារ៉ាយ បានចុះជួបជាមួយអ្នកភូមិដែលត្រូវបានបណ្តេញចេញពីលំនៅឋាន ដោយសារជម្លោះដីធ្លីដ៏រ៉ាំរ៉ៃ ក្នុងឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ បន្ទាប់ពីរដ្ឋាភិបាល បានផ្តល់សម្បទានដីសេដ្ឋកិច្ចទំហំ ៩.០០០ ហិកតា ទៅឱ្យក្រុមហ៊ុនកៅស៊ូ សីលាជាម៉ិច កាលពីឆ្នាំ២០១១។ នៅពេលនោះ អ្នកភូមិកំពុងជ្រកបណ្តោះអាសន្ននៅក្នុងព្រៃ បន្ទាប់ពីរត់គៀសខ្លួនចេញពីផ្ទះសម្បែងដោយសារខ្លាចអាជ្ញាធរចាប់ខ្លួន។ លោក កើត សារ៉ាយ បានបង្ហោះរូបភាពនៃជំនួបជាមួយអ្នកភូមិនៅលើទំព័រហ្វេសប៊ុករបស់សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ និងផ្តល់បទសម្ភាសន៍ដល់វិទ្យុអាស៊ីសេរី ដោយលោកបានលើកឡើងពីបញ្ហាប្រឈមដែលអ្នកភូមិជួបប្រទះ និងបានជំរុញឱ្យអាជ្ញាធរដោះស្រាយជម្លោះនោះ។

**៥ មេសា ២០២៤៖**

លោក កើត សារ៉ាយ ត្រូវបានមន្ត្រីស្លៀកបំពាក់ស៊ីវិលចំនួន ១០ នាក់ចាប់ខ្លួន នៅស្នាក់ការសមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ។ ការចាប់ខ្លួននេះត្រូវបានធ្វើឡើងតាមដីកាបញ្ជាឱ្យចូលខ្លួនដើម្បីសាកសួរ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពាក់ព័ន្ធដំណើររឿង ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម (តាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ)។ តំណាងអយ្យការបានចោទប្រកាន់ថាលោក កើត សារ៉ាយ បានរៀបចំផែនការបញ្ឆះបញ្ឆូលប្រជាពលរដ្ឋឱ្យកាន់កាប់ដីធ្លីដោយខុសច្បាប់ ប្រើហិង្សាប្រឆាំងនឹងអាជ្ញាធរមានសមត្ថកិច្ច និងធ្វើឱ្យប្រជាពលរដ្ឋមានការភិតភ័យចំពោះអាជ្ញាធរ ហូតរត់ទៅសម្ងំលាក់ខ្លួននៅក្នុងព្រៃ។ តំណាងអយ្យការក៏បានចោទប្រកាន់លោកថា បានបញ្ជូនរូបភាពដល់សារព័ត៌មាននៅក្រៅប្រទេស ដើម្បីផ្សព្វផ្សាយ ដែលធ្វើឱ្យយល់ច្រឡំពីមតិជាតិ និងអន្តរជាតិ មកលើថ្នាក់ដឹកនាំ ដែលនាំមានការប្រឆាំងនឹងរដ្ឋាភិបាល។

**៧ មេសា ២០២៤៖**

លោក កើត សារ៉ាយ ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះនៅមណ្ឌលអប់រំកែប្រែទី១ (ម១) ក្នុងរាជធានីភ្នំពេញ ពីបទ «ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម» និងបទ «ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម» (មាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ) ដែលចែងថា កាលណាបុគ្គលណាមួយត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមណាមួយ បុគ្គលនោះបានប្រព្រឹត្តិបទមជ្ឈិមដដែលក្នុងរយៈពេលប្រាំឆ្នាំ អតិបរិមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមថ្មីត្រូវទ្វេឡើង។ លោក កើត សារ៉ាយ រងការផ្តន្ទាទោសពីបទ ញុះញង់ កាលពីឆ្នាំ២០២១ ។

**២០ មិថុនា ២០២៤៖**

សាលាឧទ្ធរណ៍បានបដិសេធសំណើសុំនៅក្រៅឃុំរបស់លោក កើត សារ៉ាយ។

**៧ សីហា ២០២៤៖**

តុលាការកំពូលតម្កល់ការសម្រេចបដិសេធសំណើសុំនៅក្រៅឃុំរបស់លោក កើត សារ៉ាយ ដោយសំអាងនូវមូលហេតុនៃបទល្មើសមិនរាងចោលរបស់លោក។

**៦ វិច្ឆិកា ២០២៤៖**

សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសឱ្យលោក កើត សារ៉ាយ ជាប់ពន្ធនាគាររយៈពេលបួនឆ្នាំ ពីបទញុះញង់ ដែលជាទោសអតិបរមារយៈពេលពីរឆ្នាំសម្រាប់បទញុះញង់គុណនឹងពីរធ្វើឡើងតាមមាត្រា៨៨។ តុលាការក៏បានបង្គាប់ឱ្យលោកបង់ប្រាក់ពិន័យចំនួនពីរលានរៀលផងដែរ។ ក្នុងអំឡុងពេលសវនាការ បទសម្ភាសន៍ដែលលោក កើត សារ៉ាយ បានផ្តល់ឱ្យវិទ្យុអាស៊ីសេរី និងការផ្សព្វផ្សាយដែលធ្វើឡើងនៅលើទំព័រហ្វេសប៊ុករបស់សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ ពាក់ព័ន្ធនឹងជំនួបរបស់លោកជាមួយអ្នកភូមិត្រូវបានយកមកធ្វើជាភស្តុតាង។

**៣ កក្កដា ២០២៥៖**

សាលាឧទ្ធរណ៍ភ្នំពេញបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាពរបស់លោក កើត សារ៉ាយ។

**១៣ តុលា ២០២៥៖**

តុលាការកំពូលតម្កល់ការសម្រេចបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាពរបស់លោក កើត សារ៉ាយ។

**២៦ មករា ២០២៦៖**

សាលាឧទ្ធរណ៍ភ្នំពេញតម្កល់ការផ្តន្ទាទោសលោក កើត សារ៉ាយ។ មកដល់ត្រឹមថ្ងៃនេះ លោក កើត សារ៉ាយ បានជាប់ពន្ធនាគារអស់រយៈពេលជាង ៦០០ ថ្ងៃ។



CC BY NC SA